អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

| | | |
|---|---|---|
| **សកម្មភាព** | **៖ ល្បែងពាក្យផ្ទុយ** | |
| | **ចិត្តចលភាព** | |
| | បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។ | |
| | **បុរេគណិត** | |
| | រង្វាស់រង្វាល់ (បញ្ញត្តិស្តីពីរង្វាស់រង្វាល់)។ | |
| **គោលបំណង** | ៖ | |
| **(ចិត្តចលភាព)** | ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។ | |
| **(បុរេគណិត)** | ប្រាប់ពីបញ្ញត្តិ (ខ្ពស់ និងទាប  ធំ និងតូច វែង និងខ្លី រត់ និងដើរ លូន)។ | |
| **កម្រិតសិក្សា** | ៖ ទាប មធ្យម ខ្ពស់ | |
| **រយៈពេល** | ៖ ១០ នាទី | |
| **ឧបករណ៍** | ៖ ពាក្យផ្ទុយទាំងអស់(អាចជាគុណនាម ឬ កិរិយាសព្ទ)។ | |
| **ការរៀបចំ** | ៖ រៀបចំពាក្យដែលត្រូវប្រើ ពន្យល់បណ្តើរ ឱ្យក្មេងៗធ្វើតាម។ | |

**សេចក្តីណែនាំ៖**

1. និយាយថា៖ ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងពាក្យផ្ទុយ**ជាមួយកូនៗទាំងអស់គ្នា។
2. លោកគ្រូ អ្នកគ្រូឱ្យក្មេងៗទាំងអស់ឈរនៅពីមុខគាត់។
3. សួរសំណួរទៅកាន់ក្មេងៗ៖ តើពាក្យផ្ទុយនឹងពាក្យ**ទាប**គឺអ្វី?(ធ្វើកាយវិការទាក់ទងនឹងពាក្យគុណនាមមានដូចជាពាក្យ ទាប និងខ្ពស់ លឿន និងយឺត លឺខ្លាំង និងស្ងាត់...ជាដើម។
4. ល្បែងនេះមានពីសកម្មភាពពីរ សកម្មភាពស្រប និងសកម្មភាពផ្ទុយ។
5. ក្មេងៗត្រូវនិយាយតាមនឹងធ្វើកាយវិការតាមលោកគ្រូ អ្នកគ្រូ ដើម្បីឱ្យស្គាល់ច្បាស់ពីសកម្មភាព។

**សកម្មភាពប្រើពាក្យស្របតាមសកម្មភាព**

1. ឧទាហរណ៍. ពាក្យធំ លោកគ្រូ អ្នកគ្រូធ្វើលាតសន្ទឹងដៃឱ្យធំ ។
   ពាក្យតូច លោកគ្រូ អ្នកគ្រូបង្រួមដៃឱ្យតូច ។

**សកម្មភាពប្រើពាក្យផ្ទុយ**

1. ឧទាហរណ៍. ពាក្យធំ លោកគ្រូ អ្នកគ្រូត្រូវលាតសន្ទឹងដៃឱ្យធំ ។ ប៉ុន្តែសម្រាប់ ក្មេងៗត្រូវធ្វើផ្ទុយ និយាយក៏ផ្ទុយ។ ក្មេងៗត្រូវ និយាយ តូច ហើយបង្រួមដៃឱ្យតូចផ្ទុយពីលោកគ្រូ អ្នកគ្រូ។
2. បន្ទាប់ពីក្មេងៗស្គាល់ច្បាស់ពីសកម្មភាពនេះហើយ លោកគ្រូ អ្នកគ្រូអាចចាប់ផ្តើមលេងបាន។
3. នៅពេលដែលក្មេងៗណាម្នាក់ធ្វើខុសនោះ ពួកគេនឹងត្រូវដកចេញពីការលេងល្បែងនេះ ។

4. លោកគ្រូ អ្នកគ្រូបន្តការលេងល្បែងនេះរហូតដល់នៅសល់ក្មេងត្រឹមតែ ២ ឬ ៣ នាក់ ហើយពួកគេនឹងក្លាយជាអ្នកឈ្នះតែម្តង។

**ការប្រែប្រួល៖** លោកគ្រូ អ្នកគ្រូ អាចប្រើពាក្យផ្ទុយផ្សេងទៀតដែលអ្នកគិតថាល្អ។